# ចុះបើបរាជ័យ ?

ចុះបើលោក សម រង្ស៊ី ទទួលបរាជ័យជាលើកចុងក្រោយវិញ តើនរណាជាអ្នកឈ្នះ ? សត្រូវចេញមុខ ប្រឆាំងនឹង សម រង្ស៊ី គឺរបបនៅភ្នំពេញ ដូច្នេះគឺ យួន ជាអ្នកឈ្នះ ហើយជាអ្នកបន្តឈ្នះ ដែលមានសំណង់វិមាន « ឈ្នះឈ្នះ » ជាតំណាង នៃជោគជ័យ។ ជ័យជំនះថ្មីនោះ វាពិតជាមិនមែនជា ការប្រាថ្នារបស់ប្រជាជនខ្មែរភាគច្រើន។ ដូច្នេះ បរាជ័យរបស់ សម រង្ស៊ី ជាបរាជ័យ នៃប្រជាធិបតី និង ប្រជាពលរដ្ឋខ្មែរ។ មធ្យោបាយ ដែលរបបនៅភ្នំពេញ យកមកប្រើ ដើម្បីយកឈ្នះគឺ កម្លាំងអាវុធ ទប់ទល់នឹងការបះបោរអហិង្សាប្រឆាំងនឹងខ្លួន។ ជាការពិត បើរបបនេះ កើតចេញពីការបោះឆ្នោតត្រឹមត្រូវ ហើយអនុវត្តច្បាប់រដ្ឋជាសុក្រិត ការប្រើកម្លាំងអាជ្ញាធររដ្ឋ ទប់ទល់នឹងឧទ្ទាមកម្មហិង្សា វាជាការរក្សាសណ្ដាប់ធ្នាប់សាធារណៈស្របច្បាប់។ តែរបបនេះ កើតចេញពី អភិក្រមបដិប្រជាធិបតេយ្យ ហើយ សម្លាប់សេរីភាពរបស់ប្រជាពលរដ្ឋ និង សិទ្ធិធ្វើនយោបាយ ដូច្នេះ ការបះបោរ របស់ប្រជាជន វាជាផ្លូវតែមួយគត់ ព្រោះគ្រប់ការទាមទារតាមសន្តិវិធី ឱ្យមានការបោះឆ្នោតត្រឹមត្រូវ ដើម្បី ប្ដូរ ឬ រំលំ រដ្ឋាភិបាលមិនស្របច្បាប់ តាមផ្លូវច្បាប់ ត្រូវរបបនៅភ្នំពេញទុកជាមោឃៈ។ ការយកកម្លាំងកងទ័ពរបស់ខ្លួន មកការពារអំណាច នៃខ្លួន វាជាកិរិយាធម្មតារបស់អំណាចផ្ដាច់ការ

# ចុះមើលបរាជ័យ ?

តែទុកជា ការការពារជម្នានរូប ប្រឆាំងនឹងរដ្ឋប្រហារ វាគ្មានសច្ចៈភាព ព្រោះនៅក្នុងរបបផ្តាច់ការ វាគ្មាននីតិរដ្ឋនោះទេ។ ការអំពាវនាវរបស់ សម រង្ស៊ី សុំឱ្យកងប្រដាប់អាវុធ ងើបប្រឆាំងនឹងរបបផ្តាច់ការ ដែលខ្លួនកំពុងបំរើ វាគ្រាន់តែជាចម្លើយឆ្លើយតបនឹង គោលបំណងហិង្សា របស់របបផ្តាច់ការ ប្រើកម្លាំងអាវុធ សំរាប់បង្ក្រាបការបះបោរអហិង្សា នៃប្រជាជនតែប៉ុណ្ណោះ។ នៅក្នុងការលើសលន់ នៃភាសាទៅវិញទៅមករបស់ សម រង្ស៊ី និង ពួកជនផ្តាច់ការ វាស្ថិតនៅក្នុងកង្វះ សុមេធា[1] ដែលនយ:ជន[2] ទាំងឡាយ តែងតែប្រាថ្នាចង់បាន កុំឱ្យមានការក្រែវក្រោធក្នុងនយ:សំដី។ តែចំពោះ សម រង្ស៊ី គួរគាត់ត្រូវមានការប្រុងប្រយ័ត្ន បើមិនអាចជៀសបាន គួរឱ្យមានជាអប្បបរមា កុំឱ្យសំដីលើសលន់របស់គាត់ ក្លាយជាសំដីហួសហេតុ ឥតបទដ្ឋានប្រជាធិបតេយ្យ ព្រោះគាត់តាំងខ្លួនគាត់ជាអ្នកប្រជាធិបតេយ្យនិយម និង ជា ពុធជន, ពុំនោះសោធ តើគាត់មានអ្វីខុសពី ពួកជនផ្តាច់ការ។ តែសំដីអសុរោះ សព្វថ្ងៃនេះ វាក្លាយជា កីឡាជាតិរបស់យុទ្ធក:[3] ជាទូទៅ ព្រោះនៅក្នុងបរិបទនយោបាយនៅស្រុកខ្មែរ វាមានតែ ការដុតកំហឹងខ្លាំង ពីសំណាក់របបផ្តាច់ការ ដែលប្រព្រឹត្តអំពើហិង្សា និង ទុច្ចរិតគ្រប់

[1] សុមេធា : ប្រាជ្ញាដែលអាចកម្ចាត់កិលេសបាន, Art de maitriser les passions។
[2] នយ:ជន : អ្នកនយោបាយ និង ប្រើជាគុណនាម នៃពាក្យនយោបាយ។
[3] យុទ្ធក: : សកម្មជននយោបាយ, militant politique។

## ចុះមើលបរាជ័យ ?

បែបយ៉ាង ទៅលើប្រជាជន ដែលនាំឱ្យជនរងគ្រោះ គ្មានអ្វីការពារខ្លួន ប្រើសំដីអសុរោះជាចម្លើយ។ តែក៏រឿយៗដែរ យុទ្ធកៈទាំងឡាយ ប្រើជាវាចានៅក្នុងការពិភាក្សានយោបាយតែម្តងដែលបង្ហាញ នូវទិដ្ឋភាពហិង្សានៅក្នុងវាចានយោបាយ។

ទោះបីមិនចូលចិត្ត ឬ ស្អប់ ឬ មិនគាំទ្រ លោក សម រង្ស៊ី តែសព្វថ្ងៃនេះ ចង់ឬមិនចង់ គាត់ ជា អ្នកនាំពាក្យ ឬ ជា តំណាង នៃកំហឹងរបស់ប្រជាជនភាគច្រើន ដែលប្រឆាំងចេញមុខក្តី លាក់មុខក្តីនឹងអំណាចផ្តាច់ការ ហើយព្រឹត្តិការណ៍នយោបាយ ដែលកំពុងកើតឡើង វាក៏អាចទុកជាពន្លឺ នៃសេចក្តីសង្ឃឹមថ្មី ព្រោះវានឹងអាចបើកទ្វារ នៃលទ្ធភាពមួយចំនួននៅក្នុងស្រុក និងលើឆាកអន្តរជាតិ អាចនឹងមាន ដំណោះស្រាយនយោបាយដោយប្រើកម្លាំងប្រជាពលរដ្ឋ បើសិនជាកម្លាំងនេះ វានឹងមានកើតឡើងពិតប្រាកដមែន។ ត្រូវដឹងថា កំហឹង វាគ្រាន់តែជាអារម្មណ៍ តែបើអារម្មណ៍នេះ វាមិនបរិវត្តជាកម្លាំងរួមជារូបី វាក៏គ្មានអ្វីកើតឡើងនោះដែរ។ ត្រង់ចំណុចនេះឯង ដែលគេត្រូវការមាន មហាបុរស ឬ មហានារី ជាអ្នកដឹកនាំសកម្មភាពនយោបាយ ដែលជាជនមានទេពកោសល្យ អាចនឹងបរិវត្តគំនិត ឬ ផែនការល្អ ឱ្យទៅជាសកម្មភាព ដ៏ប្រសើរនៅលើសៃវៀននយោបាយ។ តើលោក សម រង្ស៊ី ជាមហាបុរស ដែលប្រជាពលរដ្ឋខ្មែរកំពុងត្រូវការឬទេ ? តើប្រជាជនខ្មែរ គាត់មានសេចក្តីក្លាហាន ដើបប្រឆាំងនឹងអំណាចផ្តាច់ការ ជា កម្លាំង

## ចុះបើបរាជ័យ ?

ពលរដ្ឋ ដែរឬទេ ? លក្ខខណ្ឌទាំងពីរនេះ វាមានទំនាក់ទំនងនឹងគ្នាដាច់ខាត។ តែទោះបីយ៉ាងណា ជនខ្មែរម្នាក់ៗ គួរកុំនាំគ្នាប្រើសំដី និង ធ្វើសកម្មភាពណាមួយ ដែលអាចជាប្រយោជន៍ដល់របបផ្តាច់ការ ព្រោះអ្នកទទួលអំណោយផលគឺ ពួកយួនកុម្មុយនិស្ត ព្រោះរបបនៅភ្នំពេញ វាគ្រាន់តែសំបក របស់យៀកណាមកុម្មុយនិស្តតែប៉ុណ្ណោះ។ តែ មិនគាំទ្រ ឬ ស្អប់ ឬ រិះគន់ សម រង្ស៊ី វាជាសិទ្ធិសេរីភាពដាច់ខាតរបស់បុគ្គលម្នាក់ៗ ហើយវាត្រូវតែមានជា ចាំបាច់នៅក្នុងលទ្ធិប្រជាធិបតេយ្យសេរី ព្រោះនរៈនេះ មិនមែនជាជន ជាពិសេសជា នយៈជន ល្អឥតខ្ចោះឡើយ, ប៉ុន្តែ គាំទ្រ របបផ្តាច់ការ វាជាការបោះបង់ចោលដោយខ្លួន នៃសិទ្ធិសេរីភាព នៃពលរដ្ឋរបស់ខ្លួន ព្រោះនៅក្នុងរបបផ្តាច់ការ បុគ្គលម្នាក់ៗ គ្មានជម្រើសអ្វីផ្សេងទៀត ក្រៅពីគាំទ្រនោះទេ៕